ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសុខាភិបាល

# សេចក្តីជូនដំណឹង

## ស្តីពី

## ការរកឃើញផលិតផល SUPER XL និង AMOUR មានផ្ទុកសារធាតុហាមឃាត់ Sildenafil

ក្រសួងសុខាភិបាល នៃព្រះរាជាណាចក្រកម្ពុជា សូមជម្រាបជូនដល់សាធារណជនទាំងអស់ឱ្យបានជ្រាបថា យោងតាមការស្រាវជ្រាវរបស់ភ្នាក់ងារត្រួតពិនិត្យឱសថ និងលទ្ធផលរបស់មជ្ឈមណ្ឌលជាតិពិសោធន៍សុខាភិបាល នៃក្រសួងសុខាភិបាល បានរកឃើញថា ផលិតផលចំនួន០២ មុខ ឈ្មោះ **១.SUPER XL ២.AMOUR** ដែលបាន និងកំពុងផ្សព្វផ្សាយលក់តាមរយៈបណ្តាញទំនាក់ទំនងសង្គម មានផ្ទុកសារជាតុ Sildenafil ដែលជាឱសថប្រើសម្រាប់វិបត្តិសរីរាង្គភេទបុរស។ ផលវិបាក នៃឱសថនេះ អាចបណ្តាលឱ្យមានផលប៉ះពាល់ដល់បេះដូង និងគ្រោះថ្នាក់ដល់អាយុជីវិតជាយថាហេតុទៀតផង។ បន្ទាប់ពីបានធ្វើការស្រាវជ្រាវ មន្ត្រីជំនាញ នៃក្រសួងសុខាភិបាល បានសហការជាមួយអង្គភាព និងអាជ្ញាធរ ពាក់ព័ន្ធ ចុះធ្វើនិយ័តកម្មនៅទីតាំងចំនួន ២ កន្លែង នៅរាជធានីភ្នំពេញ ដោយបានកសាងសំណុំរឿងបញ្ជូនជនពាក់ព័ន្ធទៅតុលាការតាមនីតិវិធីផងដែរ។

ដើម្បីចៀសវាងការប៉ះពាល់ដល់សុខភាពធ្ងន់ធ្ងរ ឬឈានដល់ការបាត់បង់អាយុជីវិត ក្រសួងសុខាភិបាល សូមជម្រាបជូនដល់បងប្អូនប្រជាពលរដ្ឋទាំងអស់ត្រូវបញ្ឈប់ការទិញ និងប្រើប្រាស់ផលិតផល **SUPER XL** និង **AMOUR** ទាំងនេះជាបន្ទាន់។ ទន្ទឹមនេះដែរ ក្រសួងសុខាភិបាលសូមជម្រាបជូនថា រាល់ផលិតផលជំនួយផ្លូវភេទគ្រប់ប្រភេទ ដែលកំពុងផ្សព្វផ្សាយលក់តាមប្រព័ន្ធអនឡាញ គឺពុំមានការអនុញ្ញាតឱ្យធ្វើការផ្សព្វផ្សាយពីក្រសួងសុខាភិបាលនោះទេ ហើយតាមការស្រាវជ្រាវកន្លងមកភាគច្រើន នៃផលិតផលទាំងនោះមិនមែនជាផលិតផលបំប៉នសុខភាពនោះទេ គឺជាទូទៅមានដាក់សារជាតុឱសថសម័យ ដែលអាចធ្វើឱ្យប៉ះពាល់ធ្ងន់ធ្ងរដល់សុខភាពអ្នកប្រើប្រាស់ ឬឈានដល់បាត់បង់អាយុជីវិតទៀតផង។ ដូច្នេះ សូមបងប្អូនប្រជាពលរដ្ឋមានការប្រុងប្រយ័ត្ន និងឈប់ជឿលើការផ្សព្វផ្សាយទាំងនោះទៀត។

ក្រសួងសុខាភិបាល តម្រូវឱ្យបុគ្គលដែលនៅតែបន្តចែកចាយ ឬលក់ផលិតផលទាំង០២ខាងលើ ឬផលិតផលជំនួយផ្លូវភេទគ្មានលេខបញ្ជិកាផ្សេងទៀត ត្រូវបញ្ឈប់ការនាំចូល ចែកចាយ ឬលក់ផលិតផលទាំងនេះជាបន្ទាន់។ ក្រសួងសុខាភិបាលនឹងមានវិធានការតឹងរ៉ឹងទៅតាមផ្លូវច្បាប់ចំពោះជនណាដែលបន្តចែកចាយ ឬលក់ផលិតផលប៉ះពាល់សុខភាពគ្មានលេខបញ្ជិកាខាងលើ ឬផលិតផលគ្មានលេខបញ្ជិកាផ្សេងទៀត ទៅតាមច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងឱសថជាធរមាន។

ក្រសួងសុខាភិបាល សង្ឃឹមថាបងប្អូនប្រជាពលរដ្ឋ អាជីវករ នឹងចូលរួមសហការអនុវត្តតាមសេចក្តីជូនដំណឹងនេះប្រកបដោយប្រសិទ្ធភាពខ្ពស់។

ថ្ងៃអង្គារ ១៣រោច ខែមាឃ ឆ្នាំរោង ឆស័ក ព.ស. ២៥៦៨

រាជធានីភ្នំពេញ ថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ ២០២៥

ក្រសួងសុខាភិបាល



អាសយដ្ឋាន៖ ដីឡូត៍លេខ៨០ វិថីសម្តេច ប៉ែន នុត (២៨៩) សង្កាត់បឹងកក់ទី២ ខណ្ឌទួលគោក រាជធានីភ្នំពេញ
ទូរស័ព្ទ៖(+៨៥៥) ២៣ ៨៨៥ ៩៧០
អ៊ីម៉ែល៖ info@moh.gov.kh
គេហទំព័រ៖ www.moh.gov.kh
តេឡេក្រាម៖ t.me/MOHCambodia

## ផលិតផលជំនួយផ្លូវភេទឈ្មោះ SUPER XL គ្មានលេខបញ្ជិកា និងមានលាយសារធាតុហាមឃាត់ SILDENAFIL






អាសយដ្ឋាន៖ ដីឡូត៍លេខ៨០ វិថីសម្តេច ប៉ែន នុត (២៨៩) សង្កាត់បឹងកក់ទី២ ខណ្ឌទួលគោក រាជធានីភ្នំពេញ
ទូរស័ព្ទ៖(+៨៥៥) ២៣ ៨៨៥ ៩៧០
អ៊ីមែល៖ info@moh.gov.kh
គេហទំព័រ៖ www.moh.gov.kh
តេឡេក្រាម៖ t.me/MOHCambodia

## ផលិតផលជំនួយផ្លូវភេទឈ្មោះ AMOUR គ្មានលេខបញ្ជិកា និងមានលាយសារធាតុហាមឃាត់ SILDENAFIL






អាសយដ្ឋាន៖ ដីឡូត៍លេខ៨០ វិថីសម្តេច ប៉ែន នុត (២៨៩) សង្កាត់បឹងកក់ទី២ ខណ្ឌទួលគោក រាជធានីភ្នំពេញ
ទូរស័ព្ទ៖(+៨៥៥) ២៣ ៨៨៥ ៩៧០
អ៊ីមែល៖ info@moh.gov.kh
គេហទំព័រ៖ www.moh.gov.kh
តេឡេក្រាម៖ t.me/MOHCambodia

# គណនីផ្សព្វផ្សាយលក់ផលិតផលជំនួយផ្លូវភេទឈ្មោះ SUPER XL និង AMOUR គ្មានលេខបញ្ជិកា និងមានលាយសារធាតុហាមឃាត់ SILDENAFIL







អាសយដ្ឋាន៖ ដីឡូត៍លេខ៨០ វិថីសម្តេច ប៉ែន នុត (២៨៩) សង្កាត់បឹងកក់ទី២ ខណ្ឌទួលគោក រាជធានីភ្នំពេញ
ទូរស័ព្ទ៖(+៨៥៥) ២៣ ៨៨៥ ៩៧០
អ៊ីម៉ែល៖ info@moh.gov.kh
គេហទំព័រ៖ www.moh.gov.kh
តេឡេក្រាម៖ t.me/MOHCambodia

# គណនីផ្សព្វផ្សាយលក់ផលិតផលជំនួយផ្លូវភេទឈ្មោះ SUPER XL និង AMOUR គ្មានលេខបញ្ជិកា និងមានលាយសារធាតុហាមឃាត់ SILDENAFIL






អាសយដ្ឋាន៖ ដីឡូត៍លេខ៨០ វិថីសម្តេច ប៉ែន នុត (២៨៩) សង្កាត់បឹងកក់ទី២ ខណ្ឌទួលគោក រាជធានីភ្នំពេញ
ទូរស័ព្ទ៖(+៨៥៥) ២៣ ៨៨៥ ៩៧០
អ៊ីមែល៖ info@moh.gov.kh
គេហទំព័រ៖ www.moh.gov.kh
តេឡេក្រាម៖ t.me/MOHCambodia